**BMI0158**

**សម្ភាសន៍ជាមួយឈ្មោះ នូ ជួង ភេទប្រុស អាយុ៥៥ឆ្នាំ**

**និង ប្រពន្ធឈ្មោះ កោ វ៉ាន់**

**មុខងារជំនាន់ខ្មែរក្រហម “ប្រជាជនធ្វើការនៅកងចល័ត ”**

**រស់នៅភូមិស្រះកើត ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ**

**ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១**

**សម្ភាសន៍ដោយៈ ឆាយ ឈុនលី**

**០០:៥០:៥៨**

**២២ទំព័រ**

ឈុនលី : ខ្ញុំសុំណែនាំបន្តិចសិនពូ ខ្ញុំឈ្មោះឈុនលី មកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយដូចពូមេភូមិបានជំរាបចឹងពួកខ្ញុំចង់ស្រាវជ្រាវទាក់ទងនឹងអាងត្រពាំងថ្មដើម្បីយកសាច់រឿងដែលខ្ញុំសំភាសន៍ជាមួយពូទៅសរសេរសៀវភៅដើម្បីចុះផ្សាយចឹងណាសពូ ហើយខ្ញុំសុំថតរូបពូដែរ អត់អីទេពូហ្អី?

ជួង : ចុះមានអី ។

ឈុនលី : ចាស!អីចឹងថ្ងៃនេះទី១៦ ២០១១ ។ ពូឈ្មោះពូពេញឈ្មោះអី?

ជួង : នូ ជួង ។

ឈុនលី : ភេទប្រុស អាយុប៉ុន្មានពូ?

ជួង : អាយុ៥៥ ។

ឈុនលី : ៥៥ឆ្នាំ នៅភូមិ?

ឈុនលី : ស្រះកើត ។

ជួង : ឃុំព្រះនេត្រព្រះ ។

ឈុនលី : ពូស្រុកកំណើតនៅឯណា?

ជួង : នៅនេះឯង ។

ឈុនលី : នៅហ្នឹងដែរ?

ជួង : នៅស្រះកើត ។

ឈុនលី : ផ្ទះហ្នឹងតែម្តង?

ជួង ៖ ទេ ផ្ទះចាស់ ផ្ទះតូចមួយ ។

ឈុនលី ៖ នៅឯណាទៅ?

ជួង ៖ ម្ដុំត្រង់នេះឯងទើបតែរើអាផ្ទះតូចចេញ ។

ឈុនលី ៖ ចាស! ពេលខ្មែរក្រហមចូលមកនៅឆ្នាំ៧៥ហ្អីពូ?

ជួង ៖ ឆ្នាំ៧៥ ។

ឈុនលី ៖ ឆ្នាំ៧៥ពូនៅធ្វើអី?

ជួង ៖ នៅបួស ។

ឈុនលី ៖ បួសនៅវត្តណា?

ជួង ៖ វត្តស្រែះនេះ ពោធិវិន័យហៅស្រែះ ។

ឈុនលី ៖ នៅវត្តពោធិ...ឈ្មោះវត្តអីគេ?

ជួង ៖ វត្តពោធិវិន័យហៅស្រែះកើត ។

ឈុនលី ៖ ពោធិវិយហៅស្រែះកើត?

ជួង ៖ បាទ!

ឈុនលី ៖ បួសបានប៉ុន្មានវស្សាទៅពូ?

ជួង ៖ បានបីវស្សា ។

ឈុនលី ៖ តាំងពីឆ្នាំណាដែលបួសហ្នឹង?

ជួង ៖ ភ្លេចឆ្នាំបាត់ហើយ បួសតាំងពីសម័យលន់ នល់ ដល់ខ្មែរក្រហមចូលមកផ្សឹកទៅ ។

ឈុនលី ៖ ពេលចូលមកដំបូងខ្មែរក្រហមធ្វើម៉េចទៅដំបូងចឹង?

ជួង ៖ គេយកមកប្រមូលផ្ដុំទៅ ផ្សឹកទៅ ។

ឈុនលី ៖ គេថាម៉េចទៅ?

ជួង ៖ ប្រាប់ថាផ្សឹក ។

ឈុនលី ៖ គេគំរាមដែរអត់ពូ?

ជួង ៖ គំរាម ។

ឈុនលី ៖ គំរាមថាម៉េចទៅពូ?

ជួង ៖ គំរាមថាបើមិនសឹកត្រូវទៅធ្វើការលើកទំនប់ដូចខបាសក ។ ដល់គំរាមហើយត្រូវ តែសឹក បើមិនសឹកមិនបាន ។

ឈុនលី ៖ ហើយមានតាំភ្លើងមានអីទេពេលចូលមក?

ជួង ៖ មាន ។

ឈុនលី ៖ ចូលមកសុទ្ធតែកាំភ្លើង?

ជួង ៖ សុទ្ធតែកាំភ្លើង ។

ឈុនលី ៖ គ្នាច្រើនទេ?

ជួង ៖ បួនដប់នាក់ ហើយពួកទាហានអីនៅក្រៅៗ ។

ឈុនលី ៖ ហើយចុះប្រជាជនក្នុងភូមិនេះម៉េចដែរ?

ជួង ៖ ប្រជាជនគេជម្លៀសចេញ ។

ឈុនលី ៖ ចឹងពួផ្សឹកភ្លាមៗម៉ង?

ជួង ៖ ផ្សឹកភ្លាមៗ ផ្សឹកហើយចូលធ្វើការចល័តបណ្តោយ ។

ឈុនលី ៖ គេចូលមកស្មើណា?

ជួង ៖ ចូលមកព្រឹកថ្ងៃបន្តិចចេញទៅវិញ ល្ងាចចូលមកទៀត ។

ឈុនលី ៖ ចូលមកបានប៉ុន្មានថ្ងៃបានផ្សឹកលោក?

ជួង ៖ បួនប្រាំថ្ងៃ ។ មកដូចថាវត្តនេះចឹងប្រមូលទៅដាក់វត្តនោះម៉ាកន្លែងផ្សឹកតែម្តង ប្រមូលតែបួនប្រាំថ្ងៃផ្សឹកអស់តែម្តង យកខោអាវផ្សឹកខោអាវខ្មៅ ។

ឈុនលី ៖ យកខោអាវខ្មៅមកឲ្យស្លៀកម៉ង?

ជួង ៖ ខោអាវខ្មៅប្រឌិប ។

ឈុនលី ៖ ហើយដល់ពេលដឹបូងចឹងគេឲ្យពូទៅធ្វើការ នៅឯណា?

ជួង ៖ គេផ្សឹករួចគេជម្លៀសឲ្យទៅលើកអាងត្រពាំងថ្ម ។

ឈុនលី ៖ គ្រាន់តែផ្សឹកភ្លាមឲ្យទៅត្រពាំងថ្មហើយ ចឹងពូទៅតាំងពី៧៥ ។ ៧៧ទេតើហ្អីពូ?

ជួង ៖ ទេ ៧៦ ៧៧ហ្នឹងហើយ ។

ឈុនលី ៖ ចុះអាមុនពេលទៅត្រពាំងថ្មនោះ មុនទៅត្រពាំងថ្មទៅណាវិញចឹង?

ជួង ៖ មានទៅណា ទៅតែត្រពាំងថ្មម៉ង ផ្សឹករួចគេបញ្ជូនទៅតែម្តង ។ មុនដំបូងដាំនៅនេះដាំថ្នាំជក់នៅនេះសិន ។

ឈុនលី ៖ នៅនេះសិន? នៅឯណា គេមានជម្លៀសទៅភូមិផ្សេង?

ជួង ៖ អត់ទេ ជម្លៀសចេញទៅក្រៅអ្នកថ្មីចូលមកបំពេញចន្លោះ ដល់អ្នកថ្មីចូលមកច្រើនវាចង្អៀត កំលោះៗជម្លៀសឲ្យទៅលើកទំនប់ប្រហែលបីខែបានរួច ។ ទៅលើកទំនប់ត្រពាំងថ្មប្រហែលបីខែបានរួច ។

ឈុនលី :	ចុះពូថាទៅដាំថ្នាំជក់ហ្នឹងដាំជាមួយគ្នាច្រើនទេ?

ជួង :	ដាំតែម្ដុំដែលគេចាត់សហករណ៍ ហើយសហករណ៍ហ្នឹងត្រូវប៉ុន្មាននាក់ ៧៥ តែទៅលើកទំនប់នោះ៧៦ ៧៧ ។

ឈុនលី :	អីចឹង៧៥ នៅធ្វើការក្នុងភូមិ?

ជួង :	៧៥ផ្សើកហើយ នៅដាំថ្នាំជក់ក្បែរវត្តនេះ ។

ឈុនលី :	ចុះមានធ្វើអីទៀតពូ មានភ្ជួរមានអីដែរអត់?

ជួង :	ហ្អស!អារឿងភ្ជួរនោះភ្ជួរហើយ ភ្ជួររួចម៉ាវាលស្រែធំធេងបានជម្លៀសទៅនោះ ចល័តទៅត្រពាំងថ្មូ ។ ភ្ជួរជាក្រុមៗ ។

ឈុនលី :	បើចឹងប្រជាជនថ្មីចូលមកដល់នេះពេលណាពូ?

ជួង :	ចូលឆ្នាំប៉ុន្មានទេចាប់ពី៧៧ហើយចឹង ។

ឈុនលី :	អីចឹងមិនមែនពេលខ្មែរក្រហមចូលមកភ្លាមទេ?

ជួង :	ខ្មែរក្រហមចប់ភ្លាមចូលភ្លាម ។

ឈុនលី :	ចង់និយាយថាមិនមែនខ្មែរក្រហមចូលមកភ្លាមអ្នកថ្មីចូលមកភ្លាមទេហ្អី ទាល់ទេ៧៧?

ជួង :	ទេ ជម្លៀសហ្អស?

ឈុនលី :	ចាស!

ជួង :	ទាល់តែរៀបចំស្រួលបួលបានជម្លៀសមក ។

ឈុនលី :	ចុះអ្នកចាស់យើងហ្នឹងជម្លៀសចេញពីភូមិអ្នកណាមកនៅក្នុងភូមិចឹង?

ជួង :	ទេ នៅតែតាមនេះអីចែកគ្នា ជម្លៀសចេញតែនារីយុវជនចេញទៅដលើកទំនប់ ។

ឈុនលី :	ចឹងចាស់ៗនៅនេះដដែល?

ជួង :	ចាស់ៗនៅនេះ ។

ឈុនលី :	ហើយគ្នាច្រើនទេពូទៅលើកទំនប់?

ជួង :	ហូស!រាប់ពាន់នាក់ ។

ឈុនលី :	រាប់ពាន់នាក់?

ជួង :	ទាំងអ្នកថ្មីផងអ្នកចាស់ផង ។

ឈុនលី :	ហើយអ្នកណាគេអ្នកហៅទៅ អ្នកណាគេអ្នកគ្រប់គ្រងនៅទំនប់?

ជួង :	ឈ្មោះ សំអាត ។

ឈុនលី :	សំអាត?

ជួង ៖ សំអាត នោះមេ ។

ឈុនលី ៖ សំអាតហ្នឹងពួកនិរតី?

ជួង ៖ និរតី ។

ឈុនលី ៖ ចុះមុននិរតីហ្នឹងមានអ្នកណានៅគ្រប់គ្រងនៅនេះ?

ជួង ៖ ពួកតាសន ពួកតារុន និរតីមកក្រោយទេ ពួកនិរតីសុទ្ធតែស្រីៗ ។

ឈុនលី ៖ ពាយ័ព្យហ្អី?

ជួង ៖ ពាយ័ព្យរំដោះក្នុងព្រៃគេយកមកកាន់កាប់នៅនេះ ។

ឈុនលី ៖ ពេលហ្នឹងពេលពួកនិរតីមកបានចាប់ពួកពាយ័ព្យយកទៅសំលាប់ចោស?

ជួង ៖ ហ្នឹងឯង ។

វ៉ាន់ ៖ ហ្នឹងឯង ពួកយោធាពាយ័ព្យដែលមកនៅបានម៉ាឆ្នាំដល់ពួកនិរតីមកវាចាប់អ្នកធំៗដែលក្តោបក្តាប់យើងតាមភូមិតាមកងយកទៅសំលាប់អស់ចឹងពួកពាយ័ព្យងាប់អស់ ។

ឈុនលី ៖ ចឹងមីងកាលជំនាន់នោះមីង...?

វ៉ាន់ ៖ មីងនៅនេះឯងនៅស្តុងជុំម៉ែៗដល់នេះគេរើសទៅធ្វើពេទ្យកូន!

ឈុនលី ៖ គេឲ្យទៅធ្វើពេទ្យ?

វ៉ាន់ ៖ នោះឯង ធ្វើពេទ្យមានធ្វើអីកូន គ្រាន់តែបុកថ្នាំសំបកថ្នាំ ធ្វើថ្នាំឲ្យគេមើលអ្នកជំងឺ ។

ឈុនលី ៖ ពេទ្យហ្នឹងចូលមកគេបង្រៀនដែរអត់?

វ៉ាន់ ៖ អត់មានបង្រៀនអីទេឲ្យទៅបុកថ្នាំវែងថ្នាំអាចម៍ទន្សាយចឹងឯង ។

ឈុនលី ៖ អាហ្នឹងពេល៧៥ចូលមកភ្លាមហ្នឹង?

វ៉ាន់ ៖ ហ្នឹងឯង៧៥ចូល៧៦ ។ ប្រជាជនឈឺនាំងអឺយ ដល់ពេលប្រជាជនថ្មីចូលមកងាប់ ចុះគ្នាមានអីស៊ី ងាប់ច្រើនណាស់ សែងម៉្ងៃៗថាសែងមួងបី ។

ឈុនលី ៖ ពេទ្យហ្នឹងនៅកន្លែងណាមន្ទីរគេ?

វ៉ាន់ ៖ ពេទ្យគេនៅស្រែះ តែមីងគេយកទៅវត្តព្រះនេត្រព្រះ ។ សែងតែខ្មោចគ្មានធ្វើការអីទេ សែងមួងបី ក្តាប៉ុណ្ណេះមួយដាក់កន់ទៅអូស ។ ទៅដល់ជីកអន្លង់ទេប៉ុណ្ណេះទៅឲ្យតែជ្រៅទៅយុវជនយើងអីក៏ចាប់បោះទៅ ។

ឈុនលី ៖ លើកដាក់អាសែងហ្នឹងទៅ?

វ៉ាន់ ៖ ហ្នឹងឯង ។

ឈុនលី ៖ តែមីងអត់អ្នកសែងទេហ្អី?

វ៉ាន់ ៖ សែងទាំងនារី យុវជនសែងដាក់តែអាក្តាហ្នឹងដល់មកវិញងាប់ទៀតហើយសែងទៀត ។

ជួង ៖ ហួស!ងាប់ច្រើនណាស់អ្នកថ្មីចូលមក ។

ឈុនលី ៖ ស្លាប់ភាគច្រើនអ្នកថ្មី?

វ៉ាន់ ៖ អ្នកថ្មី ច្រើនណាស់កូនអើយដែលអត់ឃ្លាន ។

ជួង ៖ ធ្លាប់តែស្រណុកស៊ីឆ្អែតដេកឆ្អែតដល់មកអីចេះអត់ ហើមងាប់ ។

វ៉ាន់ ៖ មកដល់ផ្ទះនេះទៀត មើលទៅក្រោមផ្ទះកូនអើយ ប្រាំមួយគ្រួសារនៅក្រោមផ្ទះ ។ យើងប្រជាជនចាស់គ្រាន់បើណាសនាងបានបបរមែនតែមានសម្លរពុកយើងធ្វើ ។ សម្លរដាក់ចានចង្កឹះចែកគ្នា៧គ្រួសារបន្តិចៗ ។ ពីរនាក់បងប្អូនស៊ីដុតទុំត្នោតថាអញអត់យំណាសកូន អញស្រណោះសង្គមនោះថាអត់ចង់បានអីទេបានតែរស់ ។ ទុំត្នោតដុតឲ្យប្អូនអង្កៀមរួចហើយហុចទៅឲ្យបងជញ្ជប់ម្នាក់ម្តង ហើយត្រួយក្រឡាញ់ម៉ាបង្កីរស្ងោរយកទឹកបេះក្រសាំងទាបម៉ាបង្កីរ ថាអញព្រឹអត្តយស្រណោះ ។ ក្រសាំងទាបយកទៅជ្រលក់អាស្ងោរត្រួយក្រឡាញ់ដាក់អំបិលតិចៗ សុទ្ធតែអ្នកថ្មីមកចែកគ្នាម្នាក់ម៉ាចានៗចែកទៅថាអគុណហើយកូនអើយ ។ បើយាយអាធា នោះយួន កូននោះបែកម៉ែស្អាតណាស់ ។ ថាអាមៀន អាធាអើយ!ហៅខ្ញុំមៀន អាធាអើយអង្គការដាក់ទិសហើយយ៉ាងម៉េចយ៉ាងម៉ាទេទៅអីស្រុក...នាំគ្នាដាក់ចំការខ្នុរដឹកទាំងឡានៗយកទៅសំលាប់នៅចំការគខ្នុរភ្នំស្វាយ ។

ឈុនលី ៖ ខាងណាអ្នកដឹកទៅ?

វ៉ាន់ ៖ ខាងនិរតី គេស្គាល់ ។

ឈុនលី ៖ ចុះម៉េចក៏មីងដឹង?

វ៉ាន់ ៖ ចុះបើដឹកទៅទាំងឡានទៅនោះណាសនាងទៅខាងលិចព្រះនេត្រព្រះឡើងកន្ទែងពេទ្យស្វាត់ណាស ។

ឈុនលី ៖ មីងឃើញហ្អី?

វ៉ាន់ ៖ អឺ អ្នកស្រុកគេខ្សឹបប្រាប់មីងថាគេយកទៅសំលាប់ចោលនៅចំការខ្នុរភ្នំស្វាយ...យកទាំងអាធាទៅទៀតគេអត់ទុកទេគេថាយួន ។ ស្រណោះ គ្មានសល់ទេកូនអើយ ។ យប់ឡើងវាហៅអញថា អាអូន!អូនឯងទៅមើលអ្នកជំងឺណាស បងទៅធ្វើការហើយ វានៅតូចដាងឯងវាហៅឯងតែអាអូន ដល់ពេលមកវិញកូនអើយដាវវាស្រោចសុទ្ធតែឈាមស្រោច វាថាមកពីធ្វើការតាមពិតវាមកពីសំលាប់មនុស្ស ដល់តែពេលប្រាំពីរថ្ងៃ ថាពេទ្យៗនាំគ្នាដឹករទេះសេះទៅដឹកកំបោរថ្ម នាងអើយ!ថាប្រេះដីអស់ អន្លង់ប្អូនជ្រុងចឹងថាប្រេះដីអស់ ។

ដល់យប់ឡើងវាថាវាចេញទៅធ្វើការតាមពិតសំលាប់មនុស្សសោះ យើងវាឲ្យនៅតែផ្ទះ ។

ឈុនលី ៖ អ្នកហ្នឹងអ្នកនិរតី?

រ៉ាន់ ៖ អ្នកនិរតី ។

ឈុនលី ៖ ឈ្មោះអីគេ?

រ៉ាន់ ៖ ច្រើនណាស់ ឈ្មោះនារីខ្ញុំ ច្រើនណាស់ ។

ឈុនលី ៖ សុទ្ធតែស្រីៗ?

រ៉ាន់ ៖ ស្រី ប្រុសមួយៗ ។

ឈុនលី ៖ ស្រីៗសំលាប់មនុស្សដែរ?

រ៉ាន់ ៖ ទាំងអស់ជុំគ្នា ប្រធានដែលធំជាងគេនៅព្រះនេត្រព្រះឈ្មោះនណុញ តានណុញមកពីនិរតីដែរ ។

ឈុនលី ៖ តាណុញ?

រ៉ាន់ ៖ ហ្នឹងឯង ។

ឈុនលី ៖ ឋានៈគាត់អីគេ?

រ៉ាន់ ៖ គេគណៈស្រុកព្រះនេត្រព្រះក្ដាប់ ។

ឈុនលី ៖ តាណុញ?

រ៉ាន់ ៖ ហ្នឹងឯង សស្គុស ស្អាតណាស់ចុះគេចិន ។

ឈុនលី ៖ ចុះស្រីៗដែលមីងថាឲ្យលាងដាវនោះ?

រ៉ាន់ ៖ ឈ្មោះមីខ្ញុំ មីខ្សាត ។

ឈុនលី ៖ ខ្ញុំ ខ្សាត?

រ៉ាន់ ៖ ហ្នឹងឯងមិនដឹងជានៅឯណាទេ ចុះស្គាល់គេហួស បើគេនៅតែគ្នាគេតែគេថាអ្នកនិរតី ។ កូនអើយ!ដែលថា អូនឯងមើលអ្នកជំងឺណាស ចាំបងទៅធ្វើការ ។

ឈុនលី ៖ និយាយសំដីពិរោះដាក់យើងហ្នឹ?

រ៉ាន់ ៖ ថាណេះអូនអើយស្រោចដៃឲ្យបង នាងអើយ!អាកាំបិតគេយកទៅអាករក៏មិនដឹងស្រោចឲ្យសុទ្ធតែឈាម ។ និយាយពីមាសគេ អាដបម្សៅប៉ុនៗណេះដាក់ក្នុងចង្កៀងសុទ្ធតែខ្សែករមាស ហើយខ្សែចង្កៀង មាសចងមកដល់បញ្ចេះសុទ្ធតែមាស មាសដាក់នៅក្នុងប្រេងកាតគេថារបស់អាចក្រព័ន្ធគេក្រវាត់ចោលហើយ ។

ឈុនលី ៖ ហើយយកទៅដាក់នៅក្នុងចង្កៀង?

វ៉ាន់ ៖ ហ្នឹងហើយ មាសច្រើនណាស់ពីដើម ក្មេងៗខ្លាចតែងាប់ នៅជុំគេក៏មិនសង្ឃឹមថាយើងបានរស់ដល់ពេលនៅៗស្រាប់តែថាវៀតណាមចូល មានអាមួយនោះត្រូវគ្នាដូចថាចូលចិត្តឯងថា វ៉ាន់!ឆាប់កៀសខ្លួនចេញទៅណោះជុំអញ ព្រោះប្រយ័ត្នយួនអាករ ។ ខ្ញុំថាទេ!ខ្ញុំអត់ទៅទេ ខ្ញុំទៅម៉ែឪខ្ញុំ ។ បានតែអង្ករម៉ាកូនចានបង្គឹះរត់មករកម៉ែនៅព្រះនេត្រព្រះ ។

ឈុនលី ៖ មីងបានតែធ្វើពេទ្យទេអត់បានទៅលើកទំនប់អីទេ?

វ៉ាន់ ៖ អត់ទៅដលើកទេគេឲ្យតែទៅព្យាបាល ទៅឃើញតែឃំណាសនាង ។

ឈុនលី ៖ អីចឹងប៉ុន្មានឆ្នាំហ្នឹងនៅតែធ្វើពេទ្យ?

វ៉ាន់ ៖ នៅតែចឹងឯងដូចថាសំណាងដែរនាងអឺយ ទៅឃើញកំលោះក្រមុំមុខស្គុទ្ធតែស្រែងអត់ទឹកមុជ នឹកឃើញតែបងប្អូនឯងអញឃំណាស ។

ឈុនលី ៖ ចុះមីងបងប្អូនប៉ុន្មាននាក់?

វ៉ាន់ ៖ ប្រាំបី ។

ឈុនលី ៖ ចុះគាត់ធ្វើអីខ្លះ?

វ៉ាន់ ៖ ប្រាំបី អាបងគេនោះចល័ត ដល់តែបងស្រីពីរមានប្តីអស់ហើយនៅតាមភូមិ គាត់ម៉ែៗនោះណាស យើងនេះពេទ្យ ដល់អាប្អូនទីមួយនោះគេរើសពេទ្យទៀតសំណាង តែតានោះទីងកូនគាត់ឈ្មោះឃីម នៅចល័ត គាត់ថាសុទ្ធតែពួកពេទ្យស្មា ។

ឈុនលី ៖ ឃីមហ្នឹងហ្អីដែលថាទៅលើកទំនប់ដែរ?

វ៉ាន់ ៖ នោះឯង រី ។

ឈុនលី ៖ គ្នាខ្ញុំកំពុងតែសំភាសន៍ដែរ ។

វ៉ាន់ ៖ ហ្នឹងឯងពុកវាទីង កូនគាត់ស្អាត តែអញប៉ាវ៉ោចឹងណាសម៉េចក៏សំណាងបានធ្វើពេទ្យ ។ មានបាននេះទេណាស កំពុងតែធ្វើការហ្នឹងគេទៅហៅគេចុះឈ្មោះតែខ្លួនគេយើងមានទៅនេះអី ។ គាត់ថាពួកមីពេទ្យស្មា ហៅខ្លួនឯងមីពេទ្យស្មា ចេះអីយកតែដបទឹកក្រូចប៉ុណ្ណេះមកគេថាបេខូបេអង ។

ឈុនលី ៖ បេដីបេអង?

វ៉ាន់ ៖ គេថាបេខូបេអង ទឹកក្រហមទឹកសចាក់ឲ្យអ្នកជំងឺ ។

ឈុនលី ៖ ឈឺអីបានចាក់អាហ្នឹង?

ភ៉ាន់ : គំរៀបជួរគ្នាចាក់ អញដឹងតែម្ចូលផ្ការាចាក់ ចាក់តែសាច់ដុំឲ្យគ្នា ចាក់ទៅនិយាយពីគ្នា អរ ។ ចេះតែធ្វើបើគេដាក់ទិសហើយធ្វើតាមគេទៅ ។

ឈុនលី : ចុះមានអ្នកណាដែលចាក់ត្រូវថ្នាំទៅស្លាប់ទេ?

ភ៉ាន់ : អត់ទេអត់មានស្លាប់ទេ ចាក់ទឹកដូងទឹកដូងឲ្យគេបង្អើបឲ្យល្អអត់អីទេ បើស្លាប់តែនឹងអត់បាយស៊ី បើចាក់អត់មានស្លាប់ទេអត់មានប្រតិកម្មអីទេ ។ យូរៗទៅក៏បានថ្នាំល្អមកម្តង ។

ឈុនលី : ថ្នាំយកមកពីណា?

ភ៉ាន់ : ថ្នាំយកមកពីខេត្តបន្ទាយមានជ័យកន្លែងខេត្តគេមក ។

ឈុនលី : កាលនោះមិនមែនឈ្មោះបន្ទាយមានជ័យទេហ្អី?

ភ៉ាន់ : ទេមិនមែនទេ មិនដឹងអីទេ ។

ឈុនលី : គេហៅតំបន់ហ្អីនៅនេះ?

ភ៉ាន់ : គេហៅតំបន់នោះឯង តំបន់ទី៤ ។

ឈុនលី : តំបន់៤ឬតំបន់៥?

ភ៉ាន់ : អឺ តំបន់៥ នេះតំបន់ទី៣ មែនតំបន់ទីប្រាំថ្មពួក សេរីសោភ័ណ្ឌ ភ្នំស្រុក ។

ឈុនលី : អ្នកណាគេអ្នកប្រធានតំបន់?

ជួង : តាហ៊ុឹង ។

ឈុនលី : តាហ៊ុឹងហ្នឹងប្រធានតំបន់?

ភ៉ាន់ : តំបន់នេះឯង ។

ឈុនលី : គាត់អ្នកស្រុកណាពូ?

ភ៉ាន់ : មិនដឹងទេ អត់មែនអ្នកនិរតីទេណាស តាហ៊ឹង គេដើរតែតាមថ្នល់ទេមិនដែលមកដល់នេះទេ ។ អញបានរស់តែប៉ុណ្ណេះអរណាសកុំអ្នកណាមកថាអីអញបោះឆ្នោត មីងមិនដែលបានបោះឲ្យអ្នកណាទេកុំថា ហ៊ុន សែនអីមីងមិនដែលបានទៅបោះ ថាខ្ញុំមិនដែលបានទៅឯណាទេ ថាតែមិនរស់ទេដូចទេវតាប្រោសមែន ។ ឃើញគេបានច្រើនខ្ញុំអត់ប្រណែនទេ តែប័ណក្រីក្រក៏មិនដែលបានស្គាល់នឹងគេទេ ។ ច្រៀងដៀលតែគេ ពួកអាចក្រព័ទ្ធអាមេរិក ពួកអាចោរកំទេចសេចក្តីឈ្លានពាន ក្រមិនដែលស្គាល់មាន អាចោរឈ្លានពានទឹកដីខ្មែរ ។

ឈុនលី : គេដេរអីចឹង?

ភ៉ាន់ : ហ្នឹងហើយច្រៀងដៀលគេ ។

ឈុនលី : ហើយមីងច្រៀងដែរ?

វ៉ាន់ : ច្រៀង គេឲ្យរាំដុតភ្លើងរាំ ។

ឈុនលី : រាំពេលណា?

វ៉ាន់ : រាំពេលយប់ ធ្វើការហើយគេដុតភ្លើងរាំ ។

ឈុនលី : គេមានថ្ងៃប្រជុំទេតើហ្អីរាំ?

វ៉ាន់ : ប្រជុំ ប្រជុំណាស់កូន ។

ឈុនលី : ប៉ុន្មានថ្ងៃប្រជុំម្ដង?

វ៉ាន់ : បីថ្ងៃប្រជុំៗកូនអើយ ។

ឈុនលី : ហើយមីងរាំទៅ?

វ៉ាន់ : រាំ ក្នាយុវជននារីទៅរាំ ។

ឈុនលី : ប៉ុន្មាននាក់រាំមីង?

វ៉ាន់ : ដាំងដប់នាក់ណាស់រាំ ស្រុះៗគ្នាគេឲ្យធ្វើកាយវិការបើត្រូវកាន់កាំភ្លើងទៀតគេឲ្យធ្វើឲ្យស្រុះៗគ្នា ។ ចំរៀងតែមួយ ស្គរតែមួយដូចលោកសូត្រធម៌ចឹង ។

ឈុនលី : ច្រៀងថាម៉េចទៅមីង ចាំទេមីងអាចច្រៀងឡើងវិញទេ?

វ៉ាន់ : ចាំមុនដំបូងគេថា និរសាអង់អាចៗមិនខ្លាចអ្វី យុវជនកម្ពុជាឃ្លាតឃ្លៃ ទោះមេឃក្ដៅត្រដាក់យ៉ាងណាក្ដីទោះបីផ្គរលាន់ភ្លៀងបែកធរណីក៏គ្មានរុញរាត្រាចចរជានិច្ច សំពាយលើខ្នងៗបំណាំងជានិច្ច ទោះយប់ថ្ងៃត្រូវតែចេញមួយរំពេច កាត់ភ្នំខ្ពស់ទាបកាត់ព្រៃក៏ស្រែក ។ ទឹកហូរខ្វួលខ្វាញ់ក៏អ្នកគ្មានគេច អ្នកប្រាជ្ញ...កាត់តំបន់ខ្មៅ ។ យុវជននិរសារីករាយ....ស្ដីទេអញចង់ភ្លេចអស់ហើយចាស់ហើយភ្លេចអស់ ។ ពួឈ្លបអើយក្លាហានៗការពារភូមិបានអាខ្មាំងមិនហ៊ានអើតក្បាល...ក៏ស្ដីទេចំរៀងច្រើនណាស់ ។

ឈុនលី : មីងចាំបានច្រើន!

វ៉ាន់ : ឲ្យតែវាវៀន វាឲ្យឯងរៀនអាពួកនិរតី និយាយពីច្រៀង ។

ឈុនលី : អ្នកណាអ្នកបង្រៀន?

ជួង : ពួកនិរតី ។

ឈុនលី : ចឹងចំរៀងហ្នឹងពួកនិរតីអ្នកនាំមកហ្អី,

វ៉ាន់ : ហ្នឹងហើយនិរតី ។ នាងអើយ!ថា កម្ពុជាអើយស្រស់ប្រឹមប្រិយ ដំណាំខៀវខ្ចីស្រងំាត់ ភ្លឺប្រឡាយថ្មីត្រង់ខ្វែងខ្វាត់ សព្វសត្វតូចធំពេញភូមិស្ថាន ។ ពពាយវាយផ្លៃក្បែរនោង ត្រ

ឡាចរយោងឃ្លោកល្ពៅ ដីប៉េងប៉ោះត្រកួនដុះពេញទី ផ្ដែក្ដិបមីពេញដេដាស ។ វារៀបរាប់សព្វគ្រប់អញចាំច្រើនណាស់ ប្រៀនម៉្វៃតែយប់ឡើងវាឲ្យអញប្រៀនហើយ ។

ឈុនលី : បីថ្ងៃម្ដង ហើយគេមានឡើងរិះគន់ខ្លួនឯងទេ?

វ៉ាន់ : រិះគន់ណាស កសាងណាស ដីប្រឡាក់ខ្នងមើលមិនឃើញ បីថ្ងៃឡើងលាងខ្លួនម្ដង ។ មានថា អ្នកក្រីក្រអឺយវេទនាម្ល៉េះទេ កូនចៅគ្មានល្ហែ...ហើយយកដៃមករីតទ្រូង ទឹកភ្នែកនឿយហត់ម្ល៉េះទេរហេមរហាម ដៃអាវរយ៉ៃបិទសឹងមិនជិតប្រាណ ម្ទេសអំបិលប្រហុកក្ដាម ប្រៃល្វីងស្រងរ៉ម...រីតទ្រូង ធ្វើតាមវាទៅស្រុះគ្នាទាំងដប់នាក់ស្រុះគ្នាណាសនាង ។ បើរាំថាលាតដៃឡើង នេះហើយស្នាដៃអាចក្រព័ទ្ធអាមេរិក វាហុតឈាមស៊ីសាច់ គក់ប្របាច់យើងគ្មានល្ហែ វាយកសង្គមនិងកម្មផលមកធ្វើឡប់ឡែ ស្គាល់មុខហើយពួកអាផ្អែពុករលួយអាវ៉ាសែ ស្រទាប់វណ្ណៈ ។ ឲ្យយើងចង្អុលអីចេះឲ្យស្រុះគ្នាកណ្ដាលភ្នក់ភ្លើង ដប់នាក់វាចង្អុលឲ្យស្រុះអីចេះ ។ ពួកអញវាកំពុងតែពេញ១៦ឆ្នាំវារើសយកទៅ នឹកម៉ែដែងនឹកអីដែងមិនទៅតាមគេ ចេះតែទៅៗ ។

ឈុនលី : ចុះឪពុកម្ដាយមីងគេជម្លៀសទៅណា?

វ៉ាន់ : នៅនេះឯងអត់ទៅណាទេ អ្នកភូមិនេះគេអត់ជម្លៀសទេយកតែកូនៗទៅឯណោះ ។

ឈុនលី : ទៅនៅភូមិអីគេអាហ្នឹង?

វ៉ាន់ : ព្រះនេត្រព្រះ ចាស់ៗនៅនេះ ក្មេងៗចេញ ។

ឈុនលី : មីងឈ្មោះអី ភ្លេចសួរឈ្មោះ?

វ៉ាន់ : វ៉ាន់ ។

ឈុនលី : មីងឈ្មោះវ៉ាន់ហ្អី? ចុះមីងនោះឈ្មោះវ៉ាន?

វ៉ាន់ : មីនោះឈ្មោះវ៉ាន ។

ឈុនលី : ត្រកូលមីងឈ្មោះអី?

វ៉ាន់ : ត្រកូលខ្ញុំ គ គ វ៉ាន់ ។

ឈុនលី : គ អក្សរគហ្នឹង?

វ៉ាន់ : ក ដាក់ស្រៈអេ ហើងស្រៈអា ។

ឈុនលី : កោ ។

វ៉ាន់ : ថាអញប្រៀនហ្អើយ! ចេះតែប្រៀនបើមិនប្រៀនខ្លាចគេយកទៅវ៉ៃចោល ។

ឈុនលីៈ ឈ្មោះវ៉ាន់ ហ្នឹងឈ្មោះតាំងពីដើមម៉ោប្ដុយ៉ាងម៉េច?

វ៉ាន់ ៖ អត់ទេ វ៉ាន់ហ្នឹងគេដាក់ពីជំនាន់អាពត ឈ្មោះពីដើមមិញ កោ ឡូម ។ អាពត មីនោះគឺម លៀង អាពតវាដាក់ វ៉ាន ។

ឈុនលីៈ ចាស!ស្គាល់គាត់តាំងពីនោះ នៅជំនាន់នោះនៅជាមួយគាត់?

វ៉ាន់ ៖ ហ្នឹងឯង ចុះអ្នកភូមិជុំគ្នាហ្នឹងឯង ។

ឈុនលីៈ ដល់ពេលជំនាន់អាពតហ្នឹងបែកគ្នា?

វ៉ាន់ ៖ អឺ!វាទៅចល័តជុំជាមួយគានេះ ។

ឈុនលីៈ ចុះមីងស្គាល់ពូយូរហើយនៅ?

វ៉ាន់ ៖ អ្នកស្រុកជុំគ្នានេះពេលបដិវត្តិ មីងគេស្នើមិនបានយកទេណានាង សួរខ្លាចអង្គការគេថា ខ្លាចសាប់ណាស សួរគេថាមិត្តបងខ្ញុំខ្លាចកសាងខ្លួនមិនទាន់បាន គេយកប្ដីទីតូចតែអញអត់ ទាន់យកទេដល់វៀតណាមចូលក៏គានេះសួរដល់៧៩បានការ ស្មៀកខ្មៅពាក់ខ្មៅការគ្មាន តែងគ្មានអីទេ ។

ឈុនលីៈ ៧៩ ចេញអាពតហើយហ្នឹង?

វ៉ាន់ ៖ ហ្នឹងហើយ ចេញអាពតហើយមានវាម៉ោមួយៗណាសមកប្រាប់ថា «វ៉ាន់អើយវ៉ាន់ ប្រយ័ត្នយួនចាប់» អាពួកនិរតីនោះមកប្រាប់ដល់ផ្ទះ ស្គាល់គ្នាធ្វើពេទ្យនោះ ។

ឈុនលីៈ ចុះពូសុំសួរពូវិញអារឿងនៅត្រពាំងថ្មណាស ទៅចឹងគំរោងគេចង់ធ្វើអីត្រពាំងថ្មហ្នឹង?

ជួង ៖ ធ្វើអាងហ្នឹងម៉ង ។

ឈុនលី ៖ គំរោងគេធ្វើអាងហ្នឹងម៉ង?

ជួង ៖ បាទ!

ឈុនលី ៖ គំរោងគេចាប់ពីឆ្នាំ៧៧?

ជួង ៖ ៧៧ ។

ឈុនលី ៖ ដើមឆ្នាំឬយ៉ាងម៉េចដែរ?

ជួង ៖ ដើមឆ្នាំ ៧៧ ៧៨ ៧៩ចប់ ។

ឈុនលី ៖ អីចឹងយូរ?

ជួង ៖ អត់ទេ បីខែច បីខែលើកអាងបីខែ បីខែទៀតទៅលើកប្រឡាយនៅព្រៃមាន់ម៉ាខែ ទៀត ។ លើកតាមប្រឡាយមាត់ថ្នល់អាថ្នល់មកពីភ្នំស្រុកមកព្រៃមាន់នេះ អាហ្នឹងម៉ាខែ បួនខែទាំងអស់ ។

ឈុនលី ៖ ពូ អាពេលលើកហ្នឹងគេបែងចែកក្រុមហ្អីយ៉ាងម៉េច គេលើកយ៉ាងម៉េច?

ជួង ៖ គេចែកតាមក្រុម ម៉ាក្រុមដប់នាក់ ម៉ាកងសាមសិបនាក់ទៅ ។

ឈុនលី ៖ ម៉ាកងសាមសិបនាក់? ចុះអ្នកណាមេកងរបស់ពូ?

ជួង ៖ សុទ្ធតែអ្នកបូព៌ាហ្នឹងឯង ។

ឈុនលី ៖ ចឹងកាលធ្វើត្រពាំងថ្មហើយហ្នឹងក្រោមការគ្រប់គ្រងរបស់និរតីហើយៗហ្អី?

ជួង ៖ គ្រប់គ្រងហើយ ។

ឈុនលី ៖ ចុះកាលពាយ័ព្យនៅអត់ទាន់ធ្វើអាងហ្នឹងហើយទេ?

ជួង ៖ មាន ពាយ័ព្យមកពួកនោះនៅក្រោមបញ្ជារបស់គេ ពួកនោះក្តាប់ពីលើពួកពាយ័ព្យទៀត ។

ឈុនលី ៖ ហួស! ហើយគេឲ្យធ្វើម្នាក់ប៉ុន្មានម៉ែត្រ?

ជួង ៖ មុនដំបូងពីរម៉ែត្រកន្លះ ពីរម៉ែត្រ ។

ឈុនលី ៖ មិនមែនបីម៉ែត្រទេ?

ជួង ៖ ពីរមែត្រថ្ងៃណោះ ស្អែកឡើងបីម៉ែត្រ ដល់ស្អែកឡើងទៀតបីម៉ែត្រកន្លះ ដល់ស្អែកមួយទៀតបួនម៉ែត្រ បួនរហូតដល់ប្រាំ ។ ប្រាំម៉ែត្រតាំងពីព្រឹកទល់ល្ងាចមិនចង់រួចទៀត ។

ឈុនលី ៖ អាហ្នឹងគេគិតម៉េចជំរៅប៉ុន្មាន ទទឹងបណ្តោយប៉ុន្មាន?

ជួង ៖ បើទទឹងពីរម៉ែត្រ បណ្តោយបួនម៉ែត្រ បួនម៉ែត្រគីប ។ បើជម្រៅតែកន្លះម៉ែត្រទេ ។

ឈុនលី ៖ ជម្រៅកន្លះម៉ែត្រ ទទឹង?

ជួង ៖ ទទឹងពីរម៉ែត្រ ។

ឈុនលី ៖ បណ្តោយ?

ជួង ៖ បណ្តោយបួនម៉ែត្រ ។

ឈុនលី ៖ ជួនទៅប្រាំម៉ែត្រចឹងទៅ?

ជួង ៖ បួនម៉ែត្រ បួនម៉ែត្រគីប អាទទឹងនេះគួបគ្នាទៅម៉ាម៉ែត្រហើយ ។ វាបីម៉ែត្រគីបទទឹងបីបណ្តោយបួន បួនម៉ែត្រគីប បណ្តោយប្រាំ ប្រាំម៉ែត្រគីប ។

ឈុនលី ៖ តែទទឹងដឹងតែពីរម៉ែត្រហើយ?

ជួង ៖ ទទឹងដឹងតែពីរម៉ែត្រ ជំរៅកន្លះម៉ែត្រ ។

ឈុនលី ៖ ហើយដល់ដីកម៉ាងៃអត់ហើយ?

ជួង ៖ ហើយដែរតែហើយឡើងយប់ ។ យប់ហើយបាយ បាយព្រឹកអាថ្ងៃម៉ោងម៉ាគាដប់បាយព្រឹក បាយល្ងាចម៉ោងដប់យប់ ។

ឈុនលី ៖ មួយថ្ងៃបានប៉ុន្មានពេលពូ?

ជួង ៖ បានតែពីរពេល ។

ឈុនលី ៖ មួយថ្ងៃបាយពីរពេល?

ជួង ៖ ពីរពេល ។

ឈុនលី ៖ ចេញទៅធ្វើការម៉ោងប៉ុន្មាន?

ជួង ៖ ឲ្យតែភ្លឺឡើងចេញហើយអត់គិតថាម៉ោងប៉ុន្មានទេ ភ្លឺឡើងដឹងតែចេញ ។

ឈុនលី ៖ ហើយស្មើណាបានៗបាយ?

ជួង ៖ ដល់ម៉ោងពីរតាដប់ ជួនកាលម៉ោងមួយ ស៊ីតែបាយហើយអត់មានបានសំរាកទេ ។ បាយហើយចុះទំនប់ទៀតទាល់តែម៉ោងដប់យប់ ។

ឈុនលី ៖ ម៉ោងដប់យប់បានៗមកវិញ?

ជួង ៖ បានៗមកវិញ ។

ឈុនលី ៖ ហើយធ្វើការដល់យប់ចឹងអត់មានបន្ថែមបុក៏បាយពេលយប់ថែមទៀត?

ជួង ៖ អត់ទេ មានតែបាយម៉ាពេលល្ងាចហ្នឹងហើយ ។

ឈុនលី ៖ បាយប៉ុន្មានពូ?

ជួង ៖ ប៉ុណ្ណេះ ហើយម្ហូបអត់មានម្ហូបទៀតមានតែទឹកប្រហុក ។

ឈុនលី ៖ ហូបទឹកប្រហុករហូតហ្នឹង?

ជួង ៖ ទឹកប្រហុករហូតអត់មានត្រីមានអីទេ ។

ឈុនលី ៖ អត់មានសំលរត្រកួនសម្លរអីទេ?

ជួង ៖ អត់មានទេ មិនមានបន្លែទេខែប្រាំង ។

ឈុនលី ៖ ខែប្រាំង?

ជួង ៖ ខែប្រាំង អ្នកណាស្លាប់ដោយសារពស់ចឹកក៏ស្លាប់ច្រើនទៀត ។ ។

ឈុនលី ៖ អ្នកណាទៅស្លាប់ដោយសារពស់ចឹក?

ជួង ៖ ពស់ចឹកសុទ្ធតែមើលអត់ជាទេ យប់ឡើងដូចថាសំរាកទៅស៊ីបាយលើកដីអត់ទាន់ហើយម៉ោងដប់យប់ទៅហូបបាយផ្កាប់បង្គីរទុកកន្លែងដីដែលជីកនឹងឯងដល់ស៊ីបាយរួចទៅបង្ហើយទៅបង្ហើយរួចទល់នឹងអាពស់ កូនក្អាត់វាទៅលេងអាដីដែលជីកសើមហ្នឹងដល់ពស់វាចេញមកស៊ីកូនក្អាត់ហ្នឹងវាសំងំនៅក្នុងបង្គីដល់តែយើងមកវិញចាប់តែបង្គីរវាចឹកបណ្តោយ ។

ឈុនលី ៖ ពស់អីគេអាហ្នឹង?

ជួង ៖ ពស់សាការចាស់ ច្រើនណាស់ ។

ឈុនលី ៖ សំបូរពស់ណាស់ហ្ន៎!

ជួង ៖ សំបូរណាស់ ។

ឈុនលី ៖ អត់មានអ្នកណាចាប់ហូបទេហ្អី?

ជួង ៖ ទេ បើឃើញថ្ងៃចាប់ហើយតែវាចេញតែយប់ ហើយមានពេលឯណាបើកាប់ដីរហូត ។ បើយើងឈឺតិចតួចធ្វើការមិនកើតយកទៅវ៉ៃចោល ។

ឈុនលី ៖ អត់មានយកទៅពេទ្យទេ?

ជួង ៖ អត់ទេ តែយើងយ៉ាប់ខ្លាំងយកទៅវ៉ៃចោលហើយ សូម្បីតែអ្នកខ្វាក់មាន់ក៏វ៉ៃកដែរ ។ អ្នកខ្វាក់មាន់យប់ ដែលថ្ងៃក្តៅខ្លាំងធ្វើការយប់ឡើងទៅខ្វាក់មាន់ប្អូនដប់នាក់ចឹងទៅមានអ្នកភ្លឺម្នាក់គេដឹកដៃទៅមុន ដើរចាប់ដងវែកឡូរយោងដើរវែកដីទៅ ។

ឈុនលី ៖ ទៅទាំងខ្វាក់ហ្នឹងទៅ?

ជួង ៖ ទៅទាំងខ្វាក់ ជួនកាលចាក់ដីរអិលអាកន្ទែងប្រាំងហ្នឹងទៅ ។

ឈុនលី ៖ អត់មានអ្នកស្លាប់ទេ?

ជួង ៖ មាន ។

ឈុនលី ៖ ធ្លាក់ទៅស្លាប់អី?

ជួង ៖ អត់ទេ ធ្លាក់ទៅថ្លោះដៃថ្លោះជើង បើអ្នកស្លាប់មានតែអ្នកពត់ធ្វើជាឈឺអីចឹងគេវ៉ៃឲ្យឃើញនៅនឹងមុខ ។

ឈុនលី ៖ មានអ្នកពត់ធ្វើឈឺទៀត?

ជួង ៖ ពត់អី ឈឺមែនហ្នឹងណាសដូចថាព្រឹកឡើងគេចេញទៅធ្វើការអស់គេដើររកមើលនៅនឹងរោងដល់ឃើញប្អូនប្រាំនាក់គេចាប់យកទៅវ៉ៃចោលទាំងអស់ ។

ឈុនលី ៖ ពូឃើញដែរ?

ជួង ៖ ឃើញ យកទៅវ៉ៃឲ្យឃើញនៅនឹងមុខ ហើយដល់ក្រុមជាមួយគ្នាហើយគ្នាឈឺទៅមិនរួច ។

ឈុនលី ៖ ស្គាល់ឈ្មោះទេពូ?

ជួង ៖ អត់ស្គាល់ទេនៅភូមិផ្សេងគ្នា ។

ឈុនលី ៖ តែធ្វើការជាមួយគ្នា?

ជួង ៖ ធ្វើការជាមួយគ្នា ។

ឈុនលី ៖ ហើយគេវ៉ៃឲ្យឃើញនៅនឹងមុខ?

ជួង ៖ វ៉ៃនៅនឹងមុខ ដូចថាយើងវែកដីមកចេះអានោះមកពីនោះអាណេះវែកពីណេះទៅវ៉ៃនៅកណ្តាល ដល់យើងវែកដីមកឲ្យចាក់នៅពីលើ ។

ឈុនលី ៖ ចឹងទំនប់ហ្នឹងមានខ្មោចកប់នៅហ្នឹង?

ជួង ៖ អូស!ច្រើនណាស់រាប់រយនាក់ខ្មោច វ៉ៃចោលរាល់ថ្ងៃ ។

ឈុនលី ៖ ពូឃើញម៉ង?

ជួង ៖ ឃើញនឹងភ្នែកគ្រប់តែគ្នា ។

ឈុនលី ៖ ខ្លាចទេ?

ជួង ៖ ទេ មិនបានទឹកនាខ្លាចអីទេ ខ្លាចតែអារឿងស្លាប់ ។

ឈុនលី ៖ ភ័យរហូតចឹង?

ជួង ៖ ភ័យតែរហូត ធ្វើការមិនដែលបានសំរាក មិនសូវមានជំងឺផងកាលនោះ ចេះតែបន់ឲ្យតែរួចទៅ ។

ឈុនលី ៖ គេឲ្យបាយម៉ាចានហ្អីពូ?

ជួង ៖ បាយម៉ាចានល្ងាចម៉ាចាន ព្រឹកម៉ាចាន ហើយទឹកអត់មានមុជទេ ។

ឈុនលី ៖ ហើយមានទឹកហូបដែរអត់?

ជួង ៖ ទឹកហូបម៉ាកងសាមសិបនាក់ចឹងគេវាល់ឲ្យម៉ាកាមែល ។

ឈុនលី ៖ ម៉ាកាមែលហ្នឹងសំរាប់ម៉ាកង?

ជួង ៖ សំរាប់ម៉ាកង ។

ឈុនលី ៖ ចុះម្នាក់បានប៉ុន្មានចឹង?

ជួង ៖ វាល់ស្លាបព្រាចែកគ្នាម្នាក់ពីរស្លាបព្រា ។

ឈុនលី ៖ ស្លាបព្រាតូចហ្នឹង?

ជួង ៖ ពីរបីស្លាបព្រាម៉ាសើម១ខ្លះទៅលួចដឹកអាទឹកបាយគេជាត់ចោលទៅដួសយកមកផឹក ។

ឈុនលី ៖ ជាត់នៅនឹងដីហ្នឹង?

ជួង ៖ ដួសនៅនឹងដីស្រែកពេក អត់ទេគេជាត់ដាក់ធុង ។

ឈុនលី ៖ ដូចជ្រូកហ្នឹង ឡើងដូចជ្រូកអស់ហើយ ។

ជួង ៖ ដូចជ្រូក វេទនាណាស់ អាទឹកមុជក៏អត់ អាទឹកផឹកក៏អត់ ។

ឈុនលី ៖ កើតចៃដែរ អត់មុជទឹកចឹងមានចៃទេពូ?

ជួង ៖ អត់មានទេ ទេដល់យូរទៅមានដែរតើ យូរទៅអាវតែល្ងាចឡើងចេញអារអំបិលស ដល់យប់ឡើងវាជោរអាជាតិអំបិលនៅនឹងអាវស្រក់មកតក់ៗ ព្រឹកឡើងពូតទៅទៀតហើយ ។

ឈុនលី ៖ ព្រលឹមឡើងរបេះអំបិល?

ជួង ៖ របេះអំបិល ពូតអាទឹកអំបិលហ្នឹងចេញពាក់ទៅទៀតហើយខ្លួនសុទ្ធតែរមាស់ឡូកឃាពេញខ្លួន ។

ឈុនលី ៖ ធំក្លិនខ្លួន?

ជួង ៖ ធំក្លិន ដូចប្រែតហើយម្នាក់ៗពេញតែខ្លួន ។ បីខែទាល់តែបានរួចអានោះ ។

ឈុនលី ៖ ស្គមខ្លាំងទេពូ?

ជួង ៖ អូសស្គម ធំតែក្បាលទេហើយនឹងក្បាលជន្គង់ទេ ។

ឈុនលី ៖ ទាំងអស់គ្នា?

ជួង ៖ ទាំងអស់គ្នា ពីបាកពេកអាយប់ក៏អត់ងងុយទៀត ។

ឈុនលី ៖ កាប់ដល់យប់ៗទៀត ។

ជួង ៖ ដល់ម៉ោងដប់អី ម៉ោងដប់មិនទាន់រួចដល់ម៉ោងម៉ាតាដប់ទៀតបន្ថែមម៉ាម៉ោងទៀត ។

ឈុនលី ៖ ចុះពូកាលនោះមានស្គាល់យាយថែមទេ?

ជួង ៖ ស្គាល់ ។

ឈុនលី ៖ ស្គាល់? យាយថែម គាត់ធ្វើអីគេ?

ជួង ៖ គណៈស្រុក ។

ឈុនលី ៖ គណៈស្រុកអីគេ?

ជួង ៖ ព្រះនេត្រព្រះតែគាត់នៅអីភ្នំលាភ ។

ឈុនលី ៖ ភ្នំលាភ ផ្ទះគាត់នៅហ្នឹង?

ជួង ៖ នៅទីនោះ ។

ឈុនលី ៖ តែគាត់កាន់ម៉ាស្រុកម៉ងហ្អី?

ជួង ៖ ម៉ាស្រុកព្រះនេត្រព្រះ ។

ឈុនលី ៖ គាត់កាចទេ យាយថែម?

ជួង ៖ ហួស!កាចណាស់ ។

ឈុនលី ៖ គាត់មកឆ្នាំណា?

ជួង ៖ ទេ មិនដឹងឆ្នាំណាទេភ្លេចហើយ ។

ឈុនលី ៖ ៧៨ ឬ៧៧?

ជួង ៖ ទេ ម៉ាជំនាន់ តារុន។

ឈុនលី ៖ តាក្រុកហ្នឹងគណៈស្រុកពីមុនហួស?

ជួង ៖ ឃុំ គណៈឃុំ។

ឈុនលី ៖ ចុះមួយទៀតថាឈ្មោះ តាយឿន ហ្អី? តាយឿន មេឃុំហ្អី គាត់របៀបជំទប់ឃុំហ្អីបើ
គិតមកដល់ឥឡូវ?

ជួង ៖ ហួស!ជំទប់ យឿន ជំទប់យ៉ត។

ឈុនលី ៖ ចុះតាវ៉ាល់?

ជួង ៖ តាវ៉ាល់និរតី។

ឈុនលី ៖ និរតីដែរ?

ជួង ៖ និរតី អ្នកទំនប់គេហៅតែទំនប់តាវ៉ាល់ ទំនប់កមបោរ។

ឈុនលី ៖ ចុះអ្នកណាគេគណៈឃុំមេរបស់ តាយឿមទៀតនោះ?

ជួង ៖ ពីសង្គមចៅហ្វាយស្រុកមិនដឹងឈ្មោះអីទេ មិនដែលស្គាល់កាលនោះតូចៗ ស្គាល់តែជំទប់
យឿនជំទប់យ៉ត ហើយប្រធានសហកណ៍ហ្នឹង តាស្វាង។

ឈុនលី ៖ តាស្វាង?

ជួង ៖ ព្រះនេត្រព្រះពីដើមមិញសម័យ តាយ៉ត។

ឈុនលី ៖ ចឹងយាយថែមមកចិតជាងហើយ ៧៧ ៧៨?

ជួង ៖ ៧៨ហើយ ៧៧។

ឈុនលី ៖ យាយថែម ពូខស្សាប់ឃើញមុខគាត់ទេ?

ជួង ៖ ឃើញអីមិនដែលមើលមុខច្បាស់ទេ។

ឈុនលី ៖ កាចហ្អី?

ជួង ៖ គាត់កបន្តាញ់សក់កន្តាញ់អីដង។

ឈុនលី ៖ យាយថែមឥឡូវនៅអន្ទង់វែង។

ជួង ៖ តាម៉ុកនៅដែរ?

ឈុនលី ៖ តាម៉ុកស្លាប់បាត់ហើយ ស្លាប់តាំងពី២០០៦។

ជួង ៖ នេះខៀវ សំផន។

ឈុនលី ៖ ចុះពូចេញពីទំនប់ពីរបីខែហ្នឹងទៅណាទៀត?

ជួង ៖ មកនេះហើយលើកហើយអានេះទៀតបាន...ទៅសាបស្រូវអីក្រោយ ។ ទេ កាលនោះ ចល័តចប់គេជម្លៀសមកជប់អីណោះ គេជប់លៀងធ្វើនំធ្វើអីរួចមក ។

ឈុនលី ៖ ធ្វើនំទៀត ជប់លៀងនៅឯណាទៅ?

ជួង ៖ នៅវត្តជប់ ។

ឈុនលី ៖ ជប់នឹងអីគេទៅឃុំហ្អី?

ជួង ៖ ជប់ភ៉ារី ។

ឈុនលី ៖ នៅឃុំជប់ភ៉ារី ពេលមកពីត្រពាំងថ្មវិញ ចុះពូមានទៅកូនខ្មែងដែរអត់?

ជួង ៖ ទៅកូនខ្មែងជាប់គ្នាជាមួយត្រពាំងថ្មនេះឯង តែពីកូនខ្មែងមកដល់អាងត្រពាំងថ្មហួសមក អាងត្រពាំងថ្មបិទតែមួយទំនប់តែមួយ ។

ឈុនលី ៖ ហើយទៅកូនខ្មែងហ្នឹងពូថាវេទនាជាងអាងត្រពាំងថ្មទៀត?

ជួង ៖ ហួស! វេទនាណាស់ ។

ឈុនលី ៖ ពិបាកអីខ្លះពូនៅនោះ?

ជួង ៖ ពិបាកអារឿងខ្លាចសត្វ
អត់មានអីហូបហើយអាដើមឈើធំៗកាប់នឹងកំលាំងមនុស្សទៀត ។

ឈុនលី ៖ កាប់ធ្វើអី?

ជួង ៖ កាប់ធ្វើផ្លូវ ។

ឈុនលី ៖ កាលនោះអត់ទាន់មានទឹកជងហ្នឹងហហ្អី?

ជួង ៖ អត់ ទំនប់នោះទំនប់តាំងពីចាស់បុរាណដើមឈើឡើងធំៗ ។

ឈុនលី ៖ ស្ពានរាបហ្អី?

ជួង ៖ ស្ពានរាប ស្ពានថ្មនោះ ស្ពានថ្មមានដើមគរម៉ាដើម ។ ជួនកាលទៅផ្កាប់មុខដួលរលេទឹង ណត់ទឹងណែង ។ បើផែនការគេដាក់ជប់ថ្ងៃ វៃសំរុំកយកប្រាំបីថ្ងៃឲ្យរួច ។

ឈុនលី ៖ ម៉េចក៏មុនផែនការចឹង?

ជួង ៖ អាប្រធានធំវាចង់យកមុខយកមាត់លើសផែនការ អាអែងអ្នកវែកអ្នកធ្វើចង់ងាប់ចង់ រស់ ។

ឈុនលី ៖ ទៅកូនខ្មែងយូរទេពូ?

ជួង ៖ ទៅម៉ាខែ ។

ឈុនលី ៖ ពូកាលនោះប្រធានក្រុមដែរហ្អី?

ជួង ៖ ប្រធានក្រុមកងតូច តែប្រធានក្រុមក៏វែកដូចតែគ្នា វែកដូចតែគ្នា ។

ឈុនលី ៖ ចុះម៉ាក្រុមហ្នឹងមានអ្នករកទឹករកអីទេ?

ជួង ៖ អត់ទេ មានចាស់ៗគាៗដែលគាត់នៅជីកអណ្តូងចាំអណ្តូង ។ វាល់ស្វាបព្រាចែកគ្នា ។

ឈុនលី ៖ ពូក្រោយមកដែលទៅមើលអាងហ្នឹងវិញដែរ?

ជួង ៖ ទៅដែរតើ ទៅយាមដប់ថ្ងៃសង្គមនេះឯង ។

ឈុនលី ៖ ម៉េចបានទៅយាមចឹង?

ជួង ៖ ទៅយាមដែលប៉ាវ៉ាដែលទៅវ៉ៃខ្មែរក្រហមនៅព្រៃ រាល់ថ្ងៃខែវស្សាពួកនេះទៅលេងតែ អីណុងឯងអាងកំពឹងពួយ អាងត្រពាំងថ្ម ។

ឈុនលី ៖ ធំជាងកំពឹងពួយទៀតហ្អីពូ?

ជួង ៖ មិនដឹងប៉ុន្មានគីឡូទេ ។

ឈុនលី ៖ ទទឹងបណ្តោយប៉ុន្មានដែរស្មានបានទេពូ? ចុះកាលពូទៅយាមហ្នឹងអត់ទេ?

ជួង ៖ គេឲ្យនៅម៉ាចំហៀងគ្រាន់តែមើលស្មានមិនត្រូវទេ មើលតែទឹក ។

ឈុនលី ៖ ដាក់កន្ទុយភ្នែក?

ជួង ៖ ដាច់កន្ទុយភ្នែកដូចទន្លេ ។

ឈុនលី ៖ ធំខ្លាំង មនុស្សប្រហែលប៉ុន្មាននាក់ទៅពូ?

ជួង ៖ រាប់ពាន់នាក់ណាសមិនតិចទេដល់រួចអស់ពាក់កណ្តាល ។

ឈុនលី ៖ ពូក្រោយមកមានដែលនិយាយរឿងរ៉ាវប្រាប់កូនចៅដែរ?

ជួង ៖ ប្រាប់ និយាយប្រាប់កូនចៅ ។

ឈុនលី ៖ ជឿដែរកូនចៅ?

ជួង ៖ បើមិនឃើញ ខ្លះក៏ជឿខ្លះក៏មិនជឿវាថាមិនដែលឃើញចេះតែថា ។

វ៉ាន់ ៖ កាលអញនាំកូនទៅដេកពេទ្យដែលម៉ូតូបុក កូននោះថា អ៊ឺ!អ៊ឹងឯងនិយាយរឿងអាពតឲ្យខ្ញុំ ស្តាប់ វាដេកកើយដៃ ក្មេងប្រុសជិទង់ក៏និយាយទៅវាស្រណោះហើយថាអ៊ឺអឺយអ៊ឺកម្ម ។

ឈុនលី ៖ ជឿដែរ?

វ៉ាន់ ៖ ជឿ!កូនអឺយអ៊ឺបានរស់ប៉ុណ្ណេះមិនចង់បានអីទេ ។

ឈុនលី ៖ ពូសព្វថ្ងៃធ្វើមេក្រុមទៀតហ្អី?

ជួង ៖ ប្រធានក្រុម ។

ឈុនលី ៖ កាលនោះមេក្រុមដែរ?

ជួង ៖ កាលនោះមេកង ។

ឈុនលី ៖ មេកងតែកងតែដប់នាក់ទេ?

ជួង ៖ សាមសិប ម៉ាក្រុមដប់នាក់ ។

ឈុនលី ៖ តាំងពី៧៩ទេតើហ្អី ចុះកាលជំនាន់នោះហ្អស?

ជួង ៖ ជំនាន់នោះគេរំលាយចោលហើយ ។

ឈុនលី ៖ ចុះកាលសម័យខ្មែរក្រហមមិនមែនមេក្រុមឯណាហ្អី?

ជួង ៖ ទេ មេកង ។

ឈុនលី ៖ តែធ្វើការដូចគ្នា?

ជួង ៖ ធ្វើការដូចគ្នាឲ្យតែក្រៅពីនិរតីហើយធ្វើការដូចគ្នា ។

ឈុនលី ៖ ចុះពូមានដឹងរឿងគេកាត់ទោសខ្មែរក្រហមទេ?

ជួង ៖ អត់ដឹងទេ ។

ឈុនលី ៖ អត់ដែលមើលទូរទស្សន៍ទេ?

ជួង ៖ ឃើញតែគេផ្សាយៗ ។

ឈុនលី ៖ ចុះធ្លាប់ឮឈ្មោះខៀវ សំផនដែរ?

ជួង ៖ ឮ ។

ឈុនលី ៖ តាម៉ុក អៀង សារី?

ជួង ៖ តាម៉ុក ។

ឈុនលី ៖ ខៀវ សំផន ហ្នឹងសព្វថ្ងៃគេកំពុងឃុំខ្លួននៅតុលាការនៅភ្នំពេញ មានខៀវ សំផន អៀង សារី អៀង ធិរិទ្ធប្រពន្ធគាត់ហើយនឹង នួន ជា ហើយតាឌុច តាឌុចហ្នឹងមេគុកទួលស្លែង ។ តាឌុចហ្នឹងរឿងក្ដីគាត់មួយតែឯងព្រោះគាត់មេគុក ហើយបួននាក់ទៀតគេកាត់ទោសរួមគ្នា ។ ហើយកាលឆ្នាំមុនហ្នឹងគេកាត់ទោស តាឌុច ៣៥ឆ្នាំតែត្រូវបានថយវិញ

ព្រោះគាត់ពីមុនមក ឆ្នាំកៅជាងកៅប្រាំបួនគេឃុំគាត់នៅតុលាការយោធាឡើងប្រាំបួនឆ្នាំចឹងដល់ពេលក្រោយមកគេកាត់កុះវិញចឹងទៅណាសនៅសល់១៩ឆ្នាំ ហើយក៏គាត់អត់ព្រមគាត់ប្ដឹងទៅទៀតហើយឮថាជិតចេញសេចក្ដីសំរេចហើយតែមិនទាន់ដឹងថ្ងៃណាទេ ។ ហើយបើរឿងក្ដីមេធំហ្នឹងចុងខែ៦នេះនៅថ្ងៃ២៧ ២៨គេចាប់ផ្ដើមបើកសវនាការមុនអង្គ

សេចក្តី គេពិភាក្សាគ្នាហើយខែក្រោយៗទៀតគេនឹងចាប់ផ្តើមកាត់ទៀតហើយ ។ ពូយល់យ៉ាងម៉េចដែរពេលដែលមានតុលាការកាត់ទោសចឹង? គាត់ចាស់ៗអស់ហើយពួកគាត់ ។

ជួង : ចាស់ហើយ បានគេកាត់ទោសចឹងទៅអរដែរមានអារម្មណ៍ថាសប្បាយចិត្ត ព្រោះធ្វើបាបគេណាស កាលគាត់ដឹកនាំស្លាប់អស់មនុស្សច្រើន ។

ឈុនលី : ពូដល់ក្រោយរបបខ្មែរក្រហមចឹងពូមានស្លប់ខោអាវពណ៌ខ្មៅទេ?

ជួង : ស្លប់ ខោខ្មៅអាវខ្មៅ តែនៅតែប្រើចឹងធ្វើការអីទៅច្រូត បាញ់ថ្នាំអី ។

ឈុនលី : ចុះពេលស្លៀកពាក់ខោអាវចឹងមាននឹកឃើញទេ?

ជួង : នឹកឃើញ ។

ឈុនលី : អីចឹងអត់ស្អប់ខោអាវពណ៌ខ្មៅទេចឹង?

ជួង : ស្អប់ដែរ តែគុំរូវពាក់ចឹង ។

ឈុនលី : ចុះមីងដល់ក្រោយរបបខ្មែរក្រហមចឹងមីងស្អប់ខោអាចវខ្មៅទេ?

ភ៉ាន់ : ដែលមិនស្អប់ហ្អស តែមានដែលទៅនឹកទៅនា ។

ឈុនលី : អាវខ្មៅណាស?

ភ៉ាន់ : ហ្នឹងហើយអាវខ្មៅ ។

ឈុនលី : ស្អប់ទេអាវខ្មៅ?

ភ៉ាន់ : អាវខ្មៅ ចុះពាក់ម៉ានេះហើយតែសព្វថ្ងៃមីងអត់ដែលពាក់ទេ ទិញតែពូដែលគាត់ប្រុសទៅវាល ។

ឈុនលី : ចុះមីងអត់ចូលចិត្តពាក់ទេ?

ភ៉ាន់ : អត់ពាក់ទេ ។

ឈុនលី : ដោយសាររបបហ្នឹងហ្អី?

ភ៉ាន់ : ហ្នឹងឯង ។

ឈុនលី : ម៉េចបានអត់ពាក់?

ភ៉ាន់ : ចេះតែប្រៀបណាស អញពុំតែបោះឆ្នោតអញខឹងជំនួសណាសធ្វើបាបឆ្អែតឆ្អន់ហើយ ។

ឈុនលី : ចឹងអគុណច្រើនពូ ពូមានលេខទូរស័ព្ទទេ?

ភ៉ាន់ : អត់មានទេ ចាស់ហើយរកលុយបញ្ចូលមិនបានទេ ។

ឈុនលី : កូនចៅប៉ុន្មាននាក់?

ភ៉ាន់ : បួននាក់ ។

ឈុនលី ៖ នៅហ្នឹងទាំងអស់ហ្អី?

រ៉ាន់ ៖ នៅនោះហើយមីទីពីរម៉ែមីនេះ មីទីបីទៅថៃអីហើយ ។

ឈុនលី ៖ ចុះបងស្រីកូនបង្កើតហ្អី?

រ៉ាន់ ៖ កូនបង្កើត ។

ឈុនលី ៖ ទីប៉ុន្មាន?

រ៉ាន់ ៖ ទីពីរ ។

ឈុនលី ៖ មានគ្រួសារហើយ?

រ៉ាន់ ៖ មាន មានកូនពីរហើយ ។

ឈុនលី ៖ នៅហ្នឹងដែរ?

រ៉ាន់ ៖ នៅហ្នឹង អាប្រុសនោះការបានកូនពីរហើយទៅនៅផ្ទះម៉ែក្មេកហើយ ។

ឈុនលី ៖ ចុះកូនពៅមានគ្រួសារហើយ?

រ៉ាន់ ៖ ទេ ។

ឈុនលី ៖ ស្រីឬប្រុស?

រ៉ាន់ ៖ ប្រុស ។

ឈុនលី ៖ អីចឹងខ្ញុំអគុណច្រើនហើយពូមីង ។

«ចប់»